# រឿង មហាចោរនៅទល់ដែន

## ភាគទី៩ រាត្រីស្ងាត់

- លោកមេឃុំ លោកជំទប់បាចទឹកឲ្យពរសព្ទសាធុការដល់គូថ្មី ដែលផ្តិតមេដៃចុះសំបុត្រអាពាហ៍ពិពាហ៍ មិនឲ្យយូរដល់តិចតួចឡើយ។ ទើបវិសេសក្វាហានឲ្យពរជ័យដល់បុត្រាបុត្រី ឲ្យបានសុខគ្រប់ប្រការ។
- សូមកូននៅជាមួយគ្នាឲ្យបានសុខ។ ឪពុកគ្មានអ្វីចង់ដៃកូនទេ ឪពុកមានតែប្រទេសខ្មែរ យើងទាំងមូលចង់ដៃកូន ។ ប្រទេសនេះមានទឹក ដី ព្រៃសព្វគ្រប់មុខ លោហធាតុគ្រប់មុខ។ កូនអាចនាំគ្នាកាប់គាស់ ចិញ្ចឹម ដាំ ថ្ការ ពុពារ ទាញផលឲ្យបានបរិបូណ៌តាមចិត្តកូន។ ប៉ុន្តែដើម្បីឲ្យផលដែលកូនរកបានមក កូនតោងធ្វើខ្លួនកូនឲ្យទៅជាម្ចាស់ស្រុកពិត។ កូន ! កូន !...

ក្នុងពេលប្រស់ទឹកឲ្យពរនេះ វិសេសក្វាហានដួលផ្ងារខ្លួនទៅក្រោយ។ លោកមេឃុំលោកជំទប់ មានន្ទ នាងទេវី នាងភួងក៏ផ្អើលឆោឡោ ខ្លះកោសខ្យល់ ខ្លះចាប់ ខ្លះប្របាច់ ខ្លះហៅ ខ្លះផ្ទុំត្រចៀក តែជីពចរវិសេសក្វាហាន ក៏ចេះតែវាយថយទៅ។ រហូតដល់ដាច់ខ្យល់សូន្យឈឹងតែម្តង។ វិសេសក្វាហានចូលកាន់មរណភាពក្នុងពេលនេះឯង។ លោកថយចេញពីពិភពលោកនេះដោយមានទឹកមុខញញឹម ព្រោះលោកបានទុកដាក់បុត្រីជាទីស្នេហារបស់លោកហើយ ញញឹមព្រោះលោកជឿថា វរលក្ខណ៍មានបង្អែកមួយដ៏មាំមួនហើយ ញញឹមដោយពេញចិត្តគ្មានអវិត្រង់ណា។

នាងទេវី និងមានន្ទប្តីប្រពន្ធថ្មី កើតទុក្ខនឹងមរណៈសញ្ញានេះយ៉ាងខ្លាំងជាងគេ។ នាងភួងឱបជើងខ្មោចយំអោក់អឿល រៀបរាប់ពីចិត្តវិសេសក្វាហាន ពីគុណសម្បត្តិវិសេសក្វាហាន។ នាងទេវីរៀបរាប់អំពីសេចក្តីសោកស្តាយដោយបិតានេះ ពុំទាន់បានឃើញនាងសុខ រឺទុក្ខយ៉ាងណាផងទៅថ្ងៃមុខ។ នាងរំជួលយោលយោគសោកយ៉ាងក្រៃអនេក។ មានន្ទមានទឹកមុខក្រៀមបំផុត។ ក្នុងពេលនោះ ជើងសេះឮសូរកុបៗផាយពីចំងាយមក។ មានន្ទប្រុងខ្លួនមើលទៅទិសដែលអស្សពាហ៍មក។ លុះមកដល់មុខខ្ទមកម្សត់ អ្នកជិះលោតចុះពីលើខ្នង

អត្ថបទដោយ៖ មាស សុភាព

អាជានេយ្យយ៉ាងរហ័ស។ បុរសមិនស្គាល់នេះមកគំនាប់មានន្ទយ៉ាងស្វាហាប់ រួចហុចសំបុត្រមួយដែលមានន្ទហែកមើលឃើញមានសេចក្ដីដូចតទៅ៖

**សិរីសោភ័ណ ថ្ងៃ ១០កើត ខែ ពិសាយ ព.ស ២៤០៨**
**ទីព្រះពន្លាជ័យព្រះកំពុត មកដល់មានន្ទមេទ័ពអានាខេត្តសិរីសោភ័ណ**

**ចូលខ្លួនមកជាប្រញាប់ គ្មានបង្អង់បានឡើយ។ រឹងទទឹង មានទោសអាជ្ញាសឹក។**
**ព្រះកំពុត**

លុះមើកូនសំបុត្រចប់ហើយ មានន្ទដកដង្ហើមធំៗ ណាមួយខ្មោចឪពុកក្មេកនៅជ្រងោ ណាមួយអាណិតដល់នាងទេវី ណាមួយព្រួយបារម្ភប្រហែលឪពុកលោកដឹងរឿងមករៀបការហើយ បានជាហៅទៅបន្ទាយយ៉ាងប្រញាប់ដូច្នោះ។ អ្នកសសៀរទៅជិតនាងទេវីកំពុងតែយំ ខ្សឹបប្រាប់ថា :

- ឪពុកបងមានសំបុត្រហៅបងយ៉ាងប្រញាប់ មានសំបុត្រនេះ។

  នាងទទួលសំបុត្រមកអាន។ នាងបែរមកកើតទុក្ខនឹងប្ដីទៀតហើយ។ ឱ !ទុក្ខអើយទុក្ខ!! គិតទៅក្នុងវដ្ដសង្សារនេះឃើញតែទុក្ខជួបតែទុក្ខ មានតែទុក្ខ។ ទុក្ខអ្វីក៏ទុក្ខម្ល៉េះ មកញាំញីនាងទេវីមួយគ្រាជាពីរគ្រា រួចមកបន្ថែមលើគ្នាគ្មានស្រាកស្រាន្តដូច្នោះ។ នាងសួរស្វាមីថា៖

- មានរឿងអ្វីបង ?
- ទេ មិនដឹងទេ តែអូនយកប្រាក់ពីរណែននេះទុកស្អែកទិញអីវ៉ាន់ និមន្តលោកឆាន់ រូបបងមកជួយធ្វើក្ការមឈូសពីព្រឹកមិនខាន។
- ចាំះ ! បងមកកុំខានណា !

  មានន្ទឮបណ្ដាំនេះព្រឺព្រួចគ្រលួចក្នុងចិត្តអាណិតភរិយា? ព្រោះភរិយានេះផ្ដាំតែប៉ុណ្ណោះឯង។ **បងមកកុំខានណា** ពាក្យនេះឮសូរធ្ងន់ក្នុងដួងចិត្តមេទ័ព

អត្ថបទដោយ៖ មាស សុភាព

ក្មេងនេះ។ ពាក្យនេះពីពេះរកតួរៀតន្ត្រីណាមកប្រៀបស្មើគ្មាន។ ពាក្យនេះពួក្ខង១ ក្នុងបេះដូង...។ ពាក្យនេះថ្មីដរាបចង់តែឮ ចង់តែស្ដាប់ ចង់តែឲ្យនាងថាម្ដងទៀត។ មានន្ទមើលមុខនាង នាងមើលមុខមានន្ទ រួចបុរសក្រោកដើរយ៉ាងលឿនទៅខាងក្រៅ ដែលអ្នកយកសំបុត្រនៅរង់ចាំ។ រួចមានន្ទប្រាប់អ្នកយកសំបុត្រថាឲ្យដើរទៅបន្ទាយវិញចុះ ។ ចំនែកអ្នកលោតលើខ្នងលេះបំផាយតម្រង់ទៅអាសនៈព្រះកំពុតជាបិតា៕

(សូមរង់ចាំតាមដានភាគទី១០ នៅសប្ដាហ៍ក្រោយ)

KHMER CIVILIZATION

អត្ថបទដោយ៖ មាស សុភាព